ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អអក

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ១៤១ សណ.១៩ អអក

ថ្ងៃព្រហស្បតិ៍ ១២កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ភ្នំពេញ, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីបញ្ជីថ្លៃលក់អគ្គិសនីដែលផ្គត់ផ្គង់អគ្គិសនីគ្រប់ប្រភេទ គ្រប់តំបន់ ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ ត្រូវអនុវត្តចំពោះអ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម និងអ្នកប្រើប្រាស់ពាណិជ្ជកម្ម សម្រាប់ឆ្នាំ ២០១៩

**យោង៖** - ប្រកាសរបស់ក្រសួងរ៉ែ និងថាមពល លេខ២៥៥.រថ.អរថ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨

- សេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ៥១៥.សរ.១៨.អអក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជម្រាបជូនសាធារណជន អ្នកប្រើប្រាស់អគ្គិសនីប្រភេទឧស្សាហកម្ម និងប្រភេទពាណិជ្ជកម្ម មេត្តាជ្រាបថា យោងតាមសេចក្តីសម្រេចកែសម្រួលបញ្ជីថ្លៃលក់អគ្គិសនី សម្រាប់លក់ឲ្យអ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម និងប្រភេទពាណិជ្ជកម្ម និងយោងតាមប្រកាសក្រសួងរ៉ែ និងថាមពល លេខ២៥៥.រថ.អរថ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ **បញ្ជីថ្លៃលក់អគ្គិសនីដែលអ្នកផ្គត់ផ្គង់អគ្គិសនីគ្រប់ប្រភេទ គ្រប់តំបន់ ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ ត្រូវអនុវត្តចំពោះអ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម និងអ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្ម សម្រាប់ឆ្នាំ ២០១៩** គិតលើបរិមាណថាមពលប្រើប្រាស់ ចាប់ពីខែមករា ឆ្នាំ២០១៩ តទៅ មានដូចខាងក្រោម ៖

| ប្រភេទអ្នកប្រើប្រាស់ និងលក្ខខណ្ឌនៃការទិញ | អត្រាថ្លៃ | សំគាល់ |
|---|---|---|
| **១.អ្នកប្រើប្រាស់ធំៗ គ្រប់ប្រភេទ ទិញអគ្គិសនីពីអនុស្ថានីយ៖** | | អ្នកប្រើប្រាស់អគ្គិសនី ដែលទិញអគ្គិសនី តាមការកំណត់ក្នុងតារាងនេះ អាចធ្វើការទូទាត់ថ្លៃអគ្គិសនី ជាប្រាក់រៀល ដោយគិតតាមអត្រាប្តូរប្រាក់ផ្លូវការ របស់អគ្គិសនីកម្ពុជា |
| -ទិញតាមទ្វាចរន្តតង់ស្យុងខ្ពស់ | 0.1170$/kWh | |
| -ទិញតាមទ្វាចរន្តតង់ស្យុងមធ្យម នៅអនុស្ថានីយក្នុងរាជធានីភ្នំពេញ | 0.1350$/kWh | |
| -ទិញតាមទ្វាចរន្តតង់ស្យុងមធ្យម នៅអនុស្ថានីយតាមខេត្ត | 0.1220$/kWh | |
| **២.អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម ៖** | | |
| -ទិញតាមខ្សែបញ្ជូនរង និងតាមខ្សែតង់ស្យុងមធ្យមនៃតំបន់ចែកចាយ | 0.1470$/kWh | |
| -ទិញក្រោមត្រង់ស្វូ ដែលបានវិនិយោគដោយខ្លួនឯង | 0.1529$/kWh | |
| -ទិញក្រោមត្រង់ស្វូ ដែលឲ្យអ្នកផ្គត់ផ្គង់វិនិយោគឲ្យ (បន្ថែមថ្លៃវិនិយោគ) | 0.1609$/kWh | |
| **៣.អ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្ម ៖** | | |
| -ទិញតាមខ្សែបញ្ជូនរង និងតាមខ្សែតង់ស្យុងមធ្យមនៃតំបន់ចែកចាយ | 0.1590$/kWh | |
| -ទិញក្រោមត្រង់ស្វូ ដែលបានវិនិយោគដោយខ្លួនឯង | 0.1654$/kWh | |
| -ទិញក្រោមត្រង់ស្វូ ដែលឲ្យអ្នកផ្គត់ផ្គង់វិនិយោគឲ្យ (បន្ថែមថ្លៃវិនិយោគ) | 0.1734$/kWh | |

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវកែងស្ពានទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៨៨៧ ៨៥៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

អាស្រ័យហេតុនេះ សូមអ្នកប្រើប្រាស់អគ្គិសនីប្រភេទខាងលើ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់អគ្គិសនីកម្ពុជា និងអ្នកផ្គត់ផ្គង់ឯកជនទាំងអស់ មេត្តាជ្រាប ជាព័ត៌មាន និងអនុវត្តឲ្យមានប្រសិទ្ធភាព។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**យឹម វិសិដ្ឋ**

ចម្លងជូន

- ក្រសួងរ៉ែ និងថាមពល

"ដើម្បីជូនជ្រាប"

- អគ្គិសនីកម្ពុជា
- អ្នកផ្គត់ផ្គង់ឯកជន

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- ឯកសារ-កាលប្បវត្តិ